# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHRC)
# បណ្តឹងលេខ១០៨៩/២០០២

**១.ពាក្យគន្លឹះ៖** សវនាការអយុត្តិធម៌, សមភាពនៃភាគី, សន្មត់ថាមិនទាន់មានទោស, សួរតទល់, ការឃាត់ខ្លួនដោយបំពារបំពាន, សវនាការក្នុងអំឡុងពេលសមស្រប, ការត្រួតពិនិត្យដោយតុលាការជាន់ខ្ពស់, អំពើទារុណកម្ម

**២. នីតិវិធី៖** អ្នកប្តឹង សញ្ជាតិអាមេរិក ត្រូវបានឃាត់ខ្លួន និងដាក់ពន្ធនាគារអស់៨ឆ្នាំ (១០ឆ្នាំ) ក្នុងប្រទេសហ្វីលីពីន មុនបញ្ជូនត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ពីបទរួមភេទជាមួយអនីតិជន (ក្រោយមកប្តូរទៅជាបទបំពារបំពានកុមារ)។ អ្នកប្តឹង បានបដិសេធការចោទប្រកាន់ គាត់បានប្តឹងជំទាស់ទៅដល់តុលាការជាន់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល) ពាក់ព័ន្ធនឹងការទទួលយកភស្តុតាងដាក់បន្ទុក ក្នុងដំណើរការនីតិវិធីចោទប្រកាន់ ប៉ុន្តែត្រូវបានបដិសេធដោយតុលាការទាំងនេះ ដោយសារមានភស្តុតាងជាច្រើន ពីអាជ្ញាធរប៉ូលីស។ បណ្តឹងក្នុងអង្គសេចក្តី ត្រូវបានប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ និងកំពូលផងដែរ អំពីការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន១០ឆ្នាំ។ តុលាការកំពូល អះអាងថា អ្នកប្តឹងមិនមានភស្តុតាងរឹងមាំ និង សាលាកំពូលពិនិត្យតែមើលអង្គច្បាប់។

អ្នកប្តឹង បានអះអាងថា បទល្មើសនេះ បង្កើតដោយប៉ូលីស។ គាត់ត្រូវបានឃាត់ខ្លួនដោយប៉ូលីសដោយគ្មានដីកា ខណៈឃើញគាត់ និងកុមារនៅក្នុងបន្ទប់ជាមួយគ្នាក្នុងភាពអាក្រាត។ កុមារជាជនរងគ្រោះបានអះអាងនៅមុខប៉ូលីស តែក្រោយមក ជនរងគ្រោះនិងម្តាយ បានអះអាងនៅមុខប៉ូលីសថា មិនមានរឿងដូចការចោទប្រកាន់ និងដូចអ្វីដែលខ្លួនបានឆ្លើយពីមុនឡើយ។ ទោះបីជាយ៉ាងនេះក្តី ក្នុងពេលសវនាការ ជនរងគ្រោះ មិនត្រូវបានចូលរួមមកឲ្យសួរដេញដោលទេ។ បន្ថែមពីលើនេះ សាក្សីផ្សេងដែលអះអាងថាដឹងរឿងនេះ ក៏មិនត្រូវបានកោះ ឬបង្ហាញខ្លួន ដើម្បីតទល់ទេ។ សវនាការ ត្រូវបានធ្វើឡើងក្រោយរយៈពេល ២ឆ្នាំ បន្ទាប់ពីឃាត់ខ្លួន។

អង្គហេតុនេះ បានបំពានមាត្រា៩(១) និង មាត្រា១៤(៣.គ) និង១៤(៣.ង) នៃកតិកាសញ្ញាពីសិទ្ធិនិងនយោបាយ។ អ្នកប្តឹង បានចោទបន្ថែមថា ការណ៍ដែលអាជ្ញាធរទទួលយកភស្តុតាងមួយ តែបដិសេធមួយ ជាការបំពានមាត្រា១៤(១) ការឃុំខ្លួន និងមិនបានពិនិត្យសុខភាពអ្នកប្តឹងត្រឹមត្រូវ ជាអំពើទារុណកម្មដែលបំពានមាត្រា៧ និង បំពានមាត្រា១៤ (៥) ដោយសារការបដិសេធរបស់តុលាការកំពូល។

## ៣. សំអាងហេតុ និងសេចក្តីសម្រេចៈ

**ក**. ការណ៍ដែលចាត់ថាសក្ខីកម្មរបស់ជនរងគ្រោះ (ជនល្មើសមិនបានប្រព្រឹត្តខុស) ដោយគ្មានការសួរតទល់ ជាភស្តុតាងលឺតគ្នា (hearsay evidence) និងមិនទទួលយក តែទទួលយកភស្តុតាង (ដាក់បន្ទុក) របស់សាក្សីដោយគ្មានការសួរតទល់ និងទទួលយកដោយចៅក្រម ជាការសម្រេចមិនមានភាពអព្យាក្រឹត្យ ដែលនេះបំពានមាត្រា១៤(១)។

**ខ**. ទម្រាំដល់ពេលសវនាការ អ្នកប្តឹងត្រូវរង់ចាំជាងពីរឆ្នាំ ដែលជាការយឺតយ៉ាវមួយ ដោយគ្មានយុត្តិកម្មពីរដ្ឋ ហើយមិនមែនដោយសារអ្នកប្តឹងធ្វើឲ្យមានភាពយឺតយ៉ាវទេ។ អង្គហេតុនេះ បំពានមាត្រា១៤(៣.គ)។

**គ**. ការខកខានរបស់អាជ្ញាធរតុលាការ ឲ្យមានការសាកសួរតទល់នឹងសាក្សីសំខាន់ (ដាក់បន្ទុក) និងជនរងគ្រោះ ជាការបំពានមាត្រា១៤(៣.ង)។

**ឃ**. រដ្ឋភាគីមិនជំទាស់ទេ ថាការឃាត់ខ្លួនគ្មានដីកា។ ករណីនេះ ត្រូវបានចាត់ថាជាការឃាត់ខ្លួនដោយបំពារបំពាន ដែលផ្ទុយនឹងមាត្រា៩។ បន្ថែមពីលើនេះ ការឃុំខ្លួនអ្នកប្តឹង មិនអនុញ្ញាតឲ្យមានការពិនិត្យសុខភាពត្រឹមត្រូវ រួមជាមួយនឹងកត្តាផ្សេងទៀត ជាទង្វើអមនុស្សធម៌ ដែលបំពានមាត្រា៧នៃកិតកាសញ្ញា។ ជាចុងក្រោយ គណៈកម្មាធិការ មិនបានរកឃើញនូវការបំពានមាត្រា១៤(៥)ទេ ដោយសាររឿងនេះ (ការផ្តន្ទាទោស) ត្រូវបានត្រួតពិនិត្យដោយ សាលាឧទ្ធរណ៍រួចហើយ។ ដូចនេះ ការបដិសេធដោយតុលាការកំពូលក៏មិនជាបញ្ហាទេ (កថាខ័ណ្ឌទី៧.៦)។

## ៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)

*គណៈកម្មាធិការសង្កេតបន្ថែមថា មាត្រា១៤(១) នៃកតិកាសញ្ញា ធានានូវភាពស្មើគ្នាក្នុងនីតិវិធី (procedural equality) ក៏ប៉ុន្តែ មិនអាចត្រូវបកស្រាយជាការធានាភាពស្មើគ្នានូវលទ្ធផល (equality of results in proceedings) មុខតុលាការមានសមត្ថកិច្ចទេ* (កថាខ័ណ្ឌទី ៦.៣)។

*គណៈកម្មាធិការ រំលឹកនូវយុត្តិសាស្ត្ររបស់ខ្លួនថា ជាទូទៅ វាសម្រាប់តុលាការរបស់រដ្ឋភាគីនៃកតិកាសញ្ញា ក្នុងការវាយតម្លៃភស្តុតាង និងអង្គហេតុ ក្នុងករណីជាក់លាក់ ទាល់តែ វាអាចច្បាស់ថា ការវាយតម្លៃគឺដោយបំពារបំពានយ៉ាងច្បាស់ ឬ វាជាការបដិសេធយុត្តិធម៌* (កថាខ័ណ្ឌទី៧.២)...ទើបគណៈកម្មាធិការ វាយតម្លៃដោយខ្លួនឯង។

ទស្សនៈទាំងស្រុងសូមមើលៈ CCPR/C/84/D/1089/2002, Rouse v. the Philippines